អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា
Kampuchea Action to Promote Education (KAPE)

# សេចក្តីណែនាំ និងឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ

## ឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ

អ្នកដេញថ្លៃទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារភស្តុតាង បង្ហាញពីលក្ខណៈសម្បត្តិរបស់ខ្លួនមានដូចខាងក្រោម៖

- វិញ្ញាបនបត្រចុះឈ្មោះក្រុមហ៊ុន ឬអាជីវកម្ម ក្នុងបញ្ជីក្រសួងពាណិជ្ជកម្ម (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- ប័ណ្ណប៉ាតង់ប្រចាំឆ្នាំ២០២៣ ឬប្រចាំឆ្នាំ២០២៤ (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាពបច្ចេកទេស និងបទពិសោធន៍ក្នុងការផ្គត់ផ្គង់របស់ខ្លួន ០១ ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់

ក្រុមហ៊ុន ឬអាជីវករ ទាំងអស់ដែលមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា ក្រុមហ៊ុន ឬអាជីវករ ដែលបានចូលរួមធ្វើការដេញថ្លៃ ជាក្រុមហ៊ុនមានសម្ព័ន្ធភាពជាមួយ ឬប្រភពតែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ។

<u>បញ្ជាក់៖</u>

- ការរៀបចំឯកសារភ្ជាប់ក្នុងការបញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ និងឯកសារសម្រង់តម្លៃ រួមទាំងពាក្យសុំចូលរួមដេញថ្លៃ (ដោយគិតជាប្រាក់រៀល) ចាប់ពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង ៥:០០នាទីល្ងាច ជាកំហិត។
- ការប្រជុំបើកកញ្ចប់ដេញថ្លៃ ដែលនឹងប្រព្រឹត្តិទៅ នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង ១០:០០នាទី ព្រឹក នៅបន្ទប់ប្រជុំការិយាល័យកណ្តាលអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) ខេត្ត កំពង់ចាម ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណសាលាគរុកោសល្យ និងវិក្រឹតការខេត្ត កំពង់ចាម) អគារលេខ៖ ៤០៥ ផ្លូវជាតិលេខ ៧ចាស់, ភូមិទី៦, សង្កាត់ វាលវង់, ក្រុង កំពង់ចាម, ខេត្ត កំពង់ចាម។
- ប្រសិនបើអ្នកដេញថ្លៃណាម្នាក់ដែលមិនបានចូលរួមប្រជុំបើកកញ្ចប់ឯកសារដេញថ្លៃទាន់ពេលវេលា ឬក៏អវត្តមានក្នុង (រយៈពេល ១៥នាទី) ឯកសារដាក់ដេញថ្លៃនោះមិនអនុញ្ញាតដាក់បញ្ចូលក្នុងការបើកឡើយ។
- រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ ត្រូវប្រែកក្នុងស្រោមបិទជិត ដោយមានចុះហត្ថលេខា និងបោះត្រារបស់ក្រុមហ៊ុន ឬអាជីវករ នៅលើស្រោមសំបុត្រ រួចបញ្ជូនមកការិយាល័យកណ្តាល អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) ដែលមានអាសយដ្ឋានស្ថិតនៅក្នុងបរិវេណសាលាគរុកោសល្យ និងវិក្រឹតការខេត្ត កំពង់ចាម) អគារលេខ៖ ៤០៥ ផ្លូវជាតិលេខ ៧ចាស់ ភូមិទី៦, សង្កាត់ វាលវង់, ក្រុង កំពង់ចាម, ខេត្ត កំពង់ចាម។
- រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ ត្រូវបញ្ចូលពន្ធអាករលើតម្លៃបន្ថែម ១០% (ដោយគិតជាប្រាក់រៀល) ហើយមិនអនុញ្ញាតឱ្យដាក់មកតាមរយៈសារអេឡិចត្រូនិច (អ៊ីមែល) ទេ។
- រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ ដែលមិនបានដាក់ជូនមកការិយាល័យកណ្តាលរបស់អង្គការ ខេប ទាន់ពេលវេលាទេ ត្រូវចាត់ទុកជាអាសាបង់។
- ចំពោះអ្នកចូលរួមប្រជុំការបើកបញ្ចប់ឯកសារដេញថ្លៃទាំងអស់ដែលជាអ្នកមកតំណាងក្រុមហ៊ុន ឬអាជីវករ ត្រូវមានលិខិតផ្ទេរសិទ្ធិ ដែលមានចុះហត្ថលេខាត្រឹមត្រូវពីប្រធានក្រុមហ៊ុន ឬម្ចាស់អាជីវកម្ម។
- យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរនៃការបើកកញ្ចប់ឯកសារដេញថ្លៃ ប្រសិនបើមានការចាំបាច់ ហើយយើងខ្ញុំនិងជូនដំណឹងទៅក្រុមហ៊ុន ឬអាជីវករ ដែលបានផ្ញើឯកសារដេញថ្លៃមកជាមុន)។
- រាល់ឯកសារដេញថ្លៃដែលបានដាក់មកហើយ គណៈកម្មការយើងខ្ញុំមិនប្រគល់ជូនត្រឡប់ទៅវិញទេ។